ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៣៧៥
ចុះថ្ងៃទី០៨-៨-២០០៨
សាលដីកា
លេខៈ ២៦ ក្រ៥.ប
ចុះថ្ងៃទី៣០-៤-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី១៨-៤-២០១៤ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៣៧៥ ចុះថ្ងៃទី ០៨-៨-២០០៨ រវាងៈ

- ជនជាប់ចោទឈ្មោះ [redacted] ជាត ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីលំនៅកំណើត [redacted] សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ [redacted] របររកស៊ីធ្វើស្រែ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

ត្រូវជាប់ចោទពីបទៈ ប្លន់ ប្រព្រឹត្តនៅភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៧-០១-២០០៧ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ទីលំនៅសព្វថ្ងៃ [redacted] ។ ៤

# ៦រឿងហេតុមានដូចតទៅ:

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៧-០១-២០០៧ របស់ឈ្មោះ [redacted] ថាវី បានបញ្ជាក់ថា កាលពីថ្ងៃទី១៧-០១-២០០៧ វេលាម៉ោង ៧.០០នាទីយប់ ខ្លួន និងប្រពន្ធរបស់ខ្លួនបានជិះម៉ូតូចេញពីខេត្តបាត់ដំបង ធ្វើដំណើរទៅផ្ទះនៅភូមិបត់ត្រង់ ស្រុកមង្គលបូរី ពេលខ្លួនជិះមកដល់ចំណុចវាលបាត់កង ស្រាប់តែមានម៉ូតូមួយគ្រឿងតាមពីក្រោយខ្លួន ពេលមកដល់ជិតពួកវាបានយកកាំភ្លើងខ្លីមកភ្ជង់ខ្លួនឲ្យឈប់ ភ្លាមនោះខ្លួនភ័យពេកក៏បានឈប់ម៉ូតូ ហើយពួកវាបានប្លន់យកម៉ូតូខ្លួនជិះតាមផ្លូវជាតិលេខ ៥ ទៅទិសខាងជើងបាត់ ចំពោះក្រុមចោរនោះ មានគ្នា ០៣នាក់ ជិះម៉ូតូមួយគ្រឿងធុនវ៉េវ ពណ៌ក្រហម ហើយម៉ូតូរបស់ខ្លួនធុនសេ ១២៥ ពណ៌ខ្មៅសេរី ២០០៥ លេខតួ ៨០៦៧៥៧៣ លេខម៉ាស៊ីន ៨០៦៧៥៧៣ ពាក់ស្លាកលេខ 1A-1769 ។ ខ្លួនសូមឲ្យសមត្ថកិច្ចជួយស្រាវជ្រាវរកម៉ូតូរបស់ខ្លួន ហើយបញ្ជូនជនល្មើសទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៣ (ក) ចុះថ្ងៃទី១៦-៦-២០០៨ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:

១- ផ្តន្ទាទោសលើៈ

ក- ឈ្មោះ [redacted] ជាត ដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួន ។

ខ- ឈ្មោះ [redacted] សារ៉ង ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួន ។

ពីបទ: [redacted] ប្រព្រឹត្តនៅភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៧-០១-២០០៧ បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និងការផ្តន្ទាទោស មានបញ្ញត្តិក្នុងមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

គ- ឈ្មោះ [redacted] សារឿន ដាក់ពន្ធនាគារកំណត់ ១៨ខែ គិតពីថ្ងៃចាប់ឃុំខ្លួន ។

ពីបទ: ប្លន់ ប្រព្រឹត្តនៅភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និងការផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២- ឲ្យឈ្មោះ [redacted] ជាត, [redacted] សារ៉ង រួមទាំងអាណាព្យាបាលរបស់ឈ្មោះ [redacted] សារឿន រួមគ្នាសំណងការខូចខាតទៅឲ្យឈ្មោះ [redacted] អិត ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.៨០០.០០០៛ (ពីរលានប្រាំបីសែនរៀល) ។

៣- ផ្តន្ទាទោសលើឈ្មោះ [redacted] សារុំ ដាក់ពន្ធនាគារកំណត់ ១ឆ្នាំ តែទោសនេះ ត្រូវព្យួរដោយកំណត់រយៈពេលសាកល្បង ០៥ឆ្នាំ គិតចាប់ពីក្រោយពេលប្រកាសសាលក្រមនេះតទៅ ពីបទ: កាន់កាប់អាវុធគ្រឿងផ្ទុះគ្មានការអនុញ្ញាត្តិ ប្រព្រឹត្តនៅភូមិថ្មី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៤-០១-២០០៧ បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និងការផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២០ ច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ និងមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ដោយសុំឲ្យព្យួរទោស ។ សំណូមពរ សុំប្រធានក្រុមប្រឹក្សាសម្រាលទោសតាមមាត្រា ៩៣ និង ៩៤ នៃក្រមព្រហ្មទណ្ឌ ។

- ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍យល់ឃើញថា:**

១- បណ្តឹងឧទ្ធរណ៍លេខ ៤៤ ចុះថ្ងៃទី២៣-៦-២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] ផាត ប្តឹងនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣(ក) ចុះថ្ងៃទី១៦-៦-២០០៨ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចជំនុំជម្រះបាន

២- តាមអង្គហេតុករណីជនល្មើសមានគ្នា ០៣នាក់ ជិះម៉ូតូម៉ាក C-125 ម៉ាកវ៉េវ បានដកកាំភ្លើងខ្លីភ្ជង់ជនរងគ្រោះយកម៉ូតូនៅភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៧-០១-២០០៧ នោះត្រូវបានសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទម្នាក់ក្នុងចំនោម ០៣នាក់ គឺឈ្មោះ [redacted] ផាត ដែលបានចូលរួមធ្វើសកម្មភាពក្នុងថ្ងៃកើតហេតុនោះ។

៣- នៅចំពោះមុខសាលាឧទ្ធរណ៍ជនជាប់ចោទឈ្មោះ [redacted] ផាត បានឆ្លើយទទួលស្គាល់អង្គហេតុខាងលើថា ខ្លួនពិតជាមានវត្តមាននៅជាមួយបក្ខពួកខ្លួន ០២នាក់ទៀត ពិតមែន តែខ្លួនប្តឹងឧទ្ធរណ៍មកនេះស្នើសុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោស ពេលនេះសាលាឧទ្ធរណ៍មិនលើកមកពិចារណាទេ ដោយហេតុថា ជនជាប់ចោទអវត្តមានទណ្ឌកម្មជិតផុតហើយ ។ ដូចនេះជនជាប់ចោទ គប្បីអនុវត្តទណ្ឌកម្មបន្តតាមការកំណត់របស់សាលាដំបូងខេត្តបាត់ដំបង នៃសាលក្រមព្រហ្មទណ្ឌលេខ ១៣ (ក) ចុះថ្ងៃទី១៦-៦-២០០៨ តទៅ។

៤- រឿងក្តីនេះត្រូវបានសាលាដំបូងលើកយកភស្តុតាងមកសំអាងសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ នឹងមិនលើកយកសំអាងហេតុដដែល មកបញ្ជាក់ជូនជាថ្មីទៀតទេ ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ១៣(ក) ចុះថ្ងៃទី១៦-៦-២០០៨ របស់សាលាដំបូងខេត្តបាត់ដំបង មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គួរតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី:**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៤ ចុះថ្ងៃទី២៣-៦-២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] ផាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣ (ក) ចុះថ្ងៃទី១៦-៦-២០០៨ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល ។

៣- បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤- សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨-៤-២០១៤ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ប្រកាសជាសាធារណៈ នៅថ្ងៃទី៣០-៤-២០១៤ ។

- បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]